ព្រះរាជសន្ទកថា

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ក្នុងព្រះរាជពិធីលៀងសាយភោជន៍ថ្វាយជាព្រះកិត្តិយស

ដោយព្រះករុណា AKIHITO ព្រះចៅអធិរាជ នៃប្រទេសជប៉ុន,

ទីក្រុងតូក្យូ ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០

---

**宮中晩餐会における**

**ノロドム・シハモニ・カンボジア国王の挨拶**

**（２０１０年5月１７日、東京）**

---

**ព្រះរាជសន្ទរកថា**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងព្រះរាជពិធីលៀងសាយភោជន៍ថ្វាយជាព្រះកិត្តិយស**
**ដោយព្រះករុណា AKIHITO ព្រះចៅអធិរាជ នៃប្រទេសជប៉ុន,**
ទីក្រុងតូក្យូ ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០

**ព្រះករុណា AKIHITO ព្រះចៅអធិរាជ** និង **ព្រះអធិរាជនី** នៃប្រទេសជប៉ុន ជាទីគោរព ស្រឡាញ់ និងរាប់អានដ៏ខ្ពង់ខ្ពស់បំផុត

ខ្ញុំ និងគណៈប្រតិភូ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានវត្តមាននៅពេលនេះ សូមសំដែងនូវកតញ្ញូតាធម៌ ប្រកបដោយសេចក្តីគោរពស្រឡាញ់ និងរាប់អានដ៏ជ្រាលជ្រៅបំផុតថ្វាយ **ព្រះចៅអធិរាជ** និង **ព្រះអធិរាជនី** នៃប្រទេសជប៉ុន ជូនចំពោះរាជរដ្ឋាភិបាល និងប្រជាជនជប៉ុនដ៏ឆ្នើម ដែលមានហឫទ័យសប្បុរសផ្តល់មហាកិត្តិយស ជាប្រវត្តិសាស្ត្រដល់ខ្ញុំ និងគណៈប្រតិភូ នូវបដិសណ្ឋារកិច្ចយ៉ាងមហោឡារិក និងកក់ក្តៅបំផុត ចាប់តាំងពីពេល ដែលខ្ញុំ បានមកដល់ទឹកដី នៃប្រទេសជប៉ុនដ៏ថ្កុំថ្កើង រុងរឿង និងការរៀបចំពិធីលៀងសាយភោជន៍ដ៏ត្រចះត្រចង់ ក្នុងបរិយាកាសបរិសុទ្ធ ពោរពេញទៅដោយមនោសញ្ចេតនា មិត្តភាព ភាតរភាពដ៏ខ្ពង់ខ្ពស់ និងពាក្យពេចន៍ មានខ្លឹមសារល្អប្រពៃ នៃព្រះរាជសុន្ទរកថា។ ខ្ញុំសូមអររព្រះរាជគុណ និងចងចាំជានិច្ចនូវបដិសណ្ឋារកិច្ចជាមិត្តភាព ដ៏វិសេសវិសាលនេះ។

ថ្ងៃនេះជាពេលវេលាដ៏មានតម្លៃជាប្រវត្តិសាស្ត្រ ដែលខ្ញុំមានកិត្តិយស បានមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅប្រទេសជប៉ុនដ៏ឧត្តុង្គឧត្តម ដែលជាមហាមិត្តដ៏យូរលង់ របស់ព្រះរាជាណាចក្រកម្ពុជា។ ទស្សនកិច្ចរបស់ខ្ញុំ នាឱកាសនេះ ជាការបន្តដ៏ប្រសើរនូវមិត្តភាពជាប្រវត្តិសាស្ត្រកម្ពុជា-ជប៉ុន របស់ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ជាទីសក្ការៈ និង **ព្រះចៅអធិរាជ** ដើម្បីឱ្យចំណងមិត្តភាព ភាតរភាពនៃប្រទេស និងប្រជាជនយើងទាំងពីរ កាន់តែល្អប្រសើរឡើងថែមទៀត។

ក្នុងឱកាសដ៏មហាប្រសើរនេះដែរ ខ្ញុំសូមពាំនាំនូវព្រះរាជបណ្តាំផ្ញើសួរសុខទុក្ខ សេចក្តីនឹករលឹក និង ព្រះពរជ័យ សិរីមង្គល អំពី **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ជាទីសក្ការៈ មកថ្វាយ **ព្រះចៅអធិរាជ** , **ព្រះអធិរាជនី** ព្រះរាជវង្សានុវង្សជប៉ុន និងជូន ឯកឧត្តមប្រធានព្រឹទ្ធសភា ឯកឧត្តមប្រធានរដ្ឋសភា ឯកឧត្តមនាយករដ្ឋមន្ត្រី ព្រមទាំង ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងបងប្អូនប្រជាជនជប៉ុនទាំងអស់។

ការផ្លាស់ប្តូរទស្សនកិច្ចផ្លូវរដ្ឋ ទៅវិញទៅមក ជាបន្តបន្ទាប់ រវាងថ្នាក់ដឹកនាំកម្ពុជា និងថ្នាក់ដឹកនាំជប៉ុន ព្រមទាំងការផ្លាស់ប្តូរទស្សនកិច្ចផ្លូវការជាច្រើនទៀត របស់ថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជា-ជប៉ុន បានធ្វើឱ្យចំណង មិត្តភាព សាមគ្គីភាព ប្រទេសយើងទាំងពីរ កាន់តែរឹងមាំទៀត ដើម្បីបង្កើនល្បឿន នៃកិច្ចសហប្រតិបត្តិការ ទ្វេភាគី លើគ្រប់វិស័យ សំរាប់ជាប្រយោជន៏រួមរបស់ប្រជាជនយើងទាំងពីរ។ ប្រជាជនកម្ពុជា ចងចាំជានិច្ចនូវ វីរភាពដ៏ឧត្តុង្គឧត្តម និងការខិតខំកសាងទំនាក់ទំនងមិត្តភាពរវាងប្រទេសយើងទាំងពីរ នៅលើមាគ៌ាសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការជាប្រវត្តិសាស្ត្រ តាំងពីដើមរៀងរហូតមកដល់ពេលបច្ចុប្បន្ននេះ ដែលមានលក្ខណៈ ល្អប្រសើរ និងជ្រាលជ្រៅបំផុត។

នៅក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ថ្វាយ **ព្រះចៅអធិរាជ ព្រះអធិរាជនី** ព្រះរាជវង្សានុវង្ស និងជូនរាជរដ្ឋាភិបាល ព្រមទាំងមហាប្រជាជនជប៉ុន ដែលបានឧបត្ថម្ភគាំទ្រ ប្រជាជនកម្ពុជា ដោយមហាសប្បុរស ក្នុងការជួយយ៉ាងសកម្មដើម្បីស្វែងរកសន្តិភាព និងការកសាងអភិវឌ្ឍ ប្រទេសកម្ពុជាទទួលបានសេចក្តីសុខ និងរីកចំរើន លើច្រើនវិស័យ។

ខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាល និងមហាប្រជាជនជប៉ុន នឹងមានសណ្តានចិត្តបន្តការចូលរួមជួយប្រជាជន កម្ពុជា លើការការពារជាតិ ការអភិវឌ្ឍសង្គមជាតិ ជាពិសេសការជួយឧបត្ថម្ភសកម្មភាពកំចាត់មីន ដែលបន្សល់ ទុកពីសង្គ្រាមជិត ៣ទសវត្ស កន្លងមក ដើម្បីរំដោះដីសំរាប់ប្រជារាស្ត្រធ្វើស្រែ-ចំការ និងដីសំរាប់ការអភិវឌ្ឍន៍ ផ្សេងៗទៀត។

ប្រជាជនកម្ពុជា សូមសំដែងនូវការកោតសរសើរ ស្ញប់ស្ញែងជាទីបំផុត ចំពោះមហាជោគជ័យក្រោម ព្រះរាជកិច្ចដឹកនាំដ៏ភ្លឺស្វាង នៃ **ព្រះចៅអធិរាជ** ឯកឧត្តមប្រធានព្រឹទ្ធសភា ឯកឧត្តមប្រធានរដ្ឋសភា និង ឯកឧត្តមនាយករដ្ឋមន្ត្រី ដោយមានការចូលរួមយ៉ាងសស្រាកសស្រាំ ពីមហាប្រជាជនជប៉ុនដ៏អង់អាចក្លាហាន បានធ្វើឱ្យប្រទេសជាតិជប៉ុន មានការលូតលាស់យ៉ាងសម្បើមលើគ្រប់វិស័យ។

ខ្ញុំសូមថ្លែងអំណរព្រះរាជគុណដ៏ជ្រាលជ្រៅបំផុត ចំពោះ **ព្រះចៅអធិរាជ** ដែលមានព្រះរាជហឫទ័យ សប្បុរស បានគួសបញ្ជាក់ថា ទស្សនកិច្ចផ្លូវរដ្ឋរបស់ខ្ញុំនាពេលនេះ នៅលើទឹកដីដែលមានកិត្យានុភាព គឺប្រទេស ជប៉ុនដ៏ថ្កុំថ្កើង រុងរឿង ជាវិភាគទានសំរាប់ពង្រឹងនូវចំណងមិត្តភាព និងភាតរភាព ជប៉ុន-កម្ពុជា និងសំរាប់ពង្រីក នូវពហុសហប្រតិបត្តិការរវាងមហាប្រជាជនជប៉ុន និងប្រជាជនកម្ពុជា ដែលជាឧត្តមប្រយោជន៏ដ៏ប្រសើរ នៃ ប្រជាជន និងប្រជាជាតិយើងទាំងពីរ។ លើសពីនេះទៅទៀត កិច្ចសហប្រតិបត្តិការរបស់ប្រទេសទាំងពីរក៏បាន ចូលរួម ចំណែកពង្រីកនូវស្ថិរភាព សំរាប់ការអភិវឌ្ឍន៏ក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោកផងដែរ។

រាជរដ្ឋាភិបាល និងមហាប្រជាជនជប៉ុន ជាមិត្តល្អ តែងតែឈរយ៉ាងរឹងមាំ ជាមួយរាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជា ដើម្បីព្រះរាជាណាចក្រកម្ពុជា មានលទ្ធភាពស្តារ និងស្ថាបនាសមិទ្ធផលនានា លើគ្រប់វិស័យ ឡើងវិញ។

ក្នុងបរិយាកាសពោរពេញទៅដោយមនោសញ្ចេតនា មិត្តភាព ភាតរភាពដ៏ជ្រាលជ្រៅ ខាងលើនេះ ខ្ញុំសូមលើកកែវភេសជ្ជៈឡើង ដើម្បី ព្រះរាជសុខភាពល្អបរិបូណ៌ ព្រះជន្មាយុយឺនយូរ សុភមង្គលដ៏ប្រសើរថ្វាយ **ព្រះចៅអធិរាជ** និង **ព្រះអធិរាជនី** ។

សូមអរព្រះរាជគុណ និងអរគុណដ៏ជ្រាលជ្រៅ